អគ្គនាយកដ្ឋានពត៌មាន និងសោតទស្សន៍
មកដល់ថ្ងៃទី: 27 មេសា 18 ម៉ោង: 04:00
លេខ: 346
អ្នកទទួល: ........ ហត្ថលេខា: ........
អ្នកប្រគល់: ........ ហត្ថលេខា: ........
លេខទូរស័ព្ទ: ........
ទៅ: ........

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧ សរណន

## សារាចរណែនាំ
## ស្តីពី
## ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី១៣២ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា តែងរៀបចំប្រារព្ធទិវាពលកម្មអន្តរជាតិ ១ ឧសភា ដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ។

ទិវាពលកម្មអន្តរជាតិ ១ ឧសភា នាឆ្នាំនេះ ប្រារព្ធឡើងក្រោមប្រធានបទ "**សន្តិភាព ស្ថិរភាព ដើម្បីការងារ និងឧបករណ៍**" ។

ដើម្បីរៀបចំការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣២ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨ នេះ ឱ្យប្រព្រឹត្តទៅបានល្អប្រសើរថែមទៀត រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដូចខាងក្រោម៖

១-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចេញសេចក្តីជូនដំណឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រប់មន្ទីររាជធានី ខេត្តក្រោមឱវាទ អង្គការវិជ្ជាជីវៈរបស់និយោជក ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ព្រមទាំងកម្មករនិយោជិតទាំងអស់ ដើម្បីរៀបចំកម្មវិធីអបអរសាទរទិវាពលកម្មអន្តរជាតិ ១ ឧសភា តាមរូបភាពការឈប់សម្រាកលំហែ ការរៀបចំកម្មវិធីកំសាន្តសប្បាយ ដើម្បីបង្កបរិយាកាសយោគយល់គ្នារវាងកម្មករនិយោជិត និងនិយោជក។ ទន្ទឹមនឹងនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំពិធីថ្នាក់ជាតិ ដែលមានការចូលរួមពីតំណាងក្រសួង ស្ថាប័នរដ្ឋ តំណាងអង្គការវិជ្ជាជីវៈ តំណាងអង្គការជាតិ និងអន្តរជាតិដែលជាដៃគូ។

២-ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធរដែនដីរាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវធានារក្សាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ក្នុងឱកាសនៃការប្រារព្ធទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០១៨ នេះ។

៣-រាជធានីភ្នំពេញ និងខេត្តទាំងអស់ ត្រូវរៀបចំអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣២ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ដោយចាត់តាំងឱ្យមានសកម្មភាពមីទ្ទិញ ការកំសាន្តសប្បាយនានារបស់កម្មករនិយោជិត និងនិយោជកនៅតាមសហគ្រាស គ្រឹះស្ថាននានា។

៤-ក្រសួងព័ត៌មាន ត្រូវណែនាំប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជនឱ្យធ្វើការផ្សព្វផ្សាយសារាចរណែនាំ សារលិខិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១៣២ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា និងសកម្មភាពមីទ្ទិញ ការកំសាន្តសប្បាយនានារបស់កម្មករនិយោជិត និងនិយោជកនៅតាមសហគ្រាស គ្រឹះស្ថាននានា។

៥-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កលក្ខណៈងាយស្រួល ក្នុងការផ្តល់ថវិកាសម្រាប់ការរៀបចំប្រារព្ធទិវាពលកម្មអន្តរជាតិ ១ ឧសភា នេះ។

៦-រាជធានីភ្នំពេញ និងខេត្តទាំងអស់ ក៏ដូចជាក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងសហគ្រាស គ្រឹះស្ថានឯកជន ត្រូវជ្រើសរើសទីតាំងសមស្រប ដូចជា ដងវិថីសំខាន់ៗ និងទីតាំងសហគ្រាស គ្រឹះស្ថាន ការដ្ឋាន និងកសិដ្ឋាន ដើម្បីធ្វើការចងបដាពាក្យស្លោកតាមខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣២ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា
- សន្តិភាព ស្ថិរភាព ដើម្បីការងារ និងមុខរបរ
- គោរពច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីសហជីព ដើម្បីធានាសិទ្ធិ និងផលប្រយោជន៍រួមរបស់កម្មករនិយោជិតនិងនិយោជក
- ចូលរួមយុទ្ធនាការគ្រោះថ្នាក់ការងារកម្រិតសូន្យ
- អភិវឌ្ឍរបបសន្តិសុខសង្គម ដើម្បីសុខុមាលភាពកម្មករនិយោជិត
- អភិវឌ្ឍជំនាញវិជ្ជាជីវៈ ដើម្បីផលិតភាព និងភាពប្រកួតប្រជែង

រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និយោជក កម្មករនិយោជិតកម្ពុជា និងពលករបរទេសទាំងអស់ ចូលរួមប្រារព្ធ និងអបអរសាទរទិវាពលកម្មអន្តរជាតិ ១ ឧសភា ក្នុងបរិយាកាសសោមនស្សរីករាយ សាមគ្គីភាព និងភាតរភាព ដើម្បីឱ្យស័ក្តិសមជាបុណ្យការងាររបស់ជាតិយើង។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានីខេត្ត ត្រូវរៀបចំចាត់តាំងអនុវត្តន៍ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃសុក្រ ៦កើត ខែចេត្រ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ